**សលាកប័ត្រព័ត៌មាន ៖** កម្រងអត្ថបទសិទ្ធិជាមូលដ្ឋាន ៖ សិទ្ធិនៅលើអ៊ីនធើណែត
**សិទ្ធិមូលដ្ឋាន ៖** សេរីភាពបញ្ចេញមតិ និងសេរីភាពខាងទទួលព័ត៌មាន
**រូបភាពរួម៖** ថ្មីៗនេះ ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ទើបតែបានអនុម័តនូវសេចក្តីសម្រេចមួយស្តីពីការលើកកម្ពស់ និងការពារសិទ្ធិមនុស្សនៅលើអ៊ីនធើណែត។ ចំណុចនេះគឺដើម្បីបញ្ជាក់ថាសិទ្ធិទាំងឡាយដែលមនុស្សមាននៅក្រៅប្រព័ន្ធអ៊ីនធើណែត ក៏គួរតែត្រូវបានគោរពនៅលើអ៊ីនធើណែតផងដែរ ដែលមានដូចជា សេរីភាពបញ្ចេញមតិ និងសេរីភាពទទួលព័ត៌មាន។ ទោះបីជាមានចលនាអន្តរជាតិសំដៅការពារសិទ្ធិ និងសេរីភាពលើប្រព័ន្ធអ៊ីនធើណែតក៏ដោយ ប៉ុន្តែរាជរដ្ឋាភិបាលកម្ពុជា (រដ្ឋាភិបាល) បានប្រកាសថ្មីៗនេះថារដ្ឋាភិបាលកំពុងតែធ្វើសេចក្តីព្រាងច្បាប់គ្រប់គ្រងប្រព័ន្ធអ៊ីនធើណែតដំបូងមួយ ដើម្បីគ្រប់គ្រង និងដាក់កំហិតមកលើការប្រើប្រាស់អ៊ីនធើណែត។ ដូច្នេះ ដោយផ្ទុយទៅនឹងនិន្នាការអន្តរជាតិ សេរីភាពបញ្ចេញមតិនៅកម្ពុជាក្នុងពេលឆាប់ៗនេះ នឹងត្រូវធ្លាក់ក្នុងការប្រឈម។

## សេចក្តីផ្តើម

សលាកប័ត្រព័ត៌មាននេះនឹងបង្ហាញពីទិដ្ឋភាពទូទៅ របស់សេចក្តីប្រកាសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ នាពេលថ្មីៗនេះ ក្នុងការការពារសិទ្ធិនៅលើអ៊ីនធើណែត និងពិចារណាមើលលើស្ថានភាពសេរីភាពបញ្ចេញមតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា (កម្ពុជា) រួមបញ្ចូលទាំងសេរីភាពបញ្ចេញមតិនៅលើអ៊ីនធើណែតផងដែរ។ សលាកប័ត្រព័ត៌មាននេះត្រូវតាក់តែងឡើងដោយ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ដែលជាអង្គការក្រៅរដ្ឋាភិបាលឯករាជ្យ មិនចូលបក្សសម្ព័ន្ធ ធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្សជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅប្រទេសកម្ពុជា។

## សេចក្តីប្រកាស L13 ស្តីពីការលើកកម្ពស់ ការការពារ និង ការប្រើប្រាស់សិទ្ធិមនុស្សនៅលើប្រព័ន្ធអ៊ីនធើណែត

រយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ អ៊ីនធើណែតបានក្លាយទៅជាវេទិកាដ៏សំខាន់មួយសម្រាប់ការជជែកពិភាក្សាជាសាធារណៈ សកម្មនិយម និងការអភិវឌ្ឍន៍។ តួនាទីរបស់អ៊ីនធើណែត និងបណ្តាញផ្សព្វផ្សាយសង្គមនៅក្នុងបដិវត្តនិទាឃរដូវអារ៉ាប់ ដែលបាននាំយកនូវលទ្ធិប្រជាធិបតេយ្យមកកាន់ប្រទេសដែលធ្លាប់ជាប្រទេសផ្តាច់ការ នៅក្នុងមជ្ឈិមបូព៌ា និងអាហ្វ្រិកខាងជើង គឺជាឧទាហរណ៍មួយដែលមិនអាចបដិសេធបាននោះទេ។ ដោយពិចារណាទៅលើការវិវត្តន៍នេះ ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បានអនុម័តសេចក្តីប្រកាស ស្តីពីការលើកកម្ពស់ ការការពារ និងការប្រើប្រាស់សិទ្ធិមនុស្សនៅលើប្រព័ន្ធអ៊ីនធើណែត (សេចក្តីប្រកាស) កាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១២។ សេចក្តីប្រកាសនេះ មានគោលបំណងពង្រីកនូវបញ្ញត្តសេរីភាពបញ្ចេញមតិ និងសិទ្ធិសេរីភាពដែលពាក់ព័ន្ធផ្សេងៗ ដូចដែលបានការពារនៅក្នុងមាត្រា១៩ នៃ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដើម្បីរួមបញ្ចូលទាំងសេរីភាពលើអ៊ីនធើណែតផងដែរ។ សេចក្តីប្រកាសនេះចែងថា "ការប្រើប្រាស់សិទ្ធិមនុស្ស ជាពិសេសសិទ្ធិសេរីភាពបញ្ចេញមតិ នៅលើអ៊ីនធើណែត គឺជាបញ្ហាដែលទាក់ទាញចំណាប់អារម្មណ៍ និងមានសារៈសំខាន់កាន់តែខ្លាំង ដោយសារតែមានការកើនឡើងនៃការវិវត្តន៍ផ្នែកបច្ចេកវិទ្យា ដែលអនុញ្ញាតឲ្យបុគ្គលម្នាក់ៗនៅលើពិភពលោកអាចប្រើប្រាស់បច្ចេកវិជ្ជា ព័ត៌មាន និង ទូរគមនាគមន៍បែបថ្មី" ។

## សេរីភាពបញ្ចេញមតិ និងសេរីភាពទទួលព័ត៌មាន

មាត្រា៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (រដ្ឋធម្មនុញ្ញ) បានធានាសិទ្ធិទាំងឡាយដែលបានចែងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងបាន

បញ្ចូលសិទ្ធិទាំងនេះទៅក្នុងច្បាប់ជាតិកម្ពុជា។ មាត្រា៥១ នៃរដ្ឋធម្មនុញ្ញ ក៏បានចែងជាពិសេសស្តីពីសិទ្ធិសេរីភាពបញ្ចេញមតិផងដែរ។ ខណៈពេលដែលនៅមិនទាន់មាននីតិកម្មជាក់លាក់ណាមួយដើម្បីការពារសិទ្ធិសេរីភាពទទួលព័ត៌មាន ឬ "សិទ្ធិដឹង" នៅកម្ពុជា ច្បាប់បណ្ណសារ (ឆ្នាំ ២០០៥) បានចែងពីការអាចស្វែងរកបាននូវ "ឯកសារសាធារណៈ" និងច្បាប់ស្តីពីរបបសារព័ត៌មាន (ឆ្នាំ១៩៩៥) បានទទួលស្គាល់ពីសិទ្ធិសារព័ត៌មានដើម្បីអាចទទួលយកនូវឯកសាររបស់រដ្ឋាភិបាល។ ទោះបីជាមាននីតិកម្មធានារួចហើយក៏ដោយ ប៉ុន្តែស្ថានភាពបញ្ចេញមតិនៅកម្ពុជាគឺមានលក្ខណៈគួរឲ្យព្រួយបារម្ភ។ អ្នកដែលបញ្ចេញមតិមិនស្របតែងតែប្រឈមនឹងការសម្លុត ការគំរាមកំហែង ឬក៏ការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌ។ បន្ថែមពីលើនោះទៀត រដ្ឋាភិបាលបានគ្រប់គ្រងយ៉ាងតឹងរ៉ឹងមកលើប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី ដែលមានដូចជា សារព័ត៌មាន វិទ្យុ និងទូរទស្សន៍ជាដើម។ ផ្ទុយនឹងស្ថានភាពបែបនេះ ដែលឃើញថាប្រព័ន្ធផ្សព្វផ្សាយដទៃត្រូវបានដាក់កំហិតយ៉ាងធ្ងន់ធ្ងរ អ៊ិនធើណែតគឺជាជម្រើសដែលមានលក្ខណៈសេរីគួរសម សម្រាប់បុគ្គលណាដែលមានបំណងរិះគន់ឲ្យមានការផ្លាស់ប្តូរ និងសម្រាប់ឲ្យអ្នកនយោបាយគណបក្សប្រឆាំងជំរុញបញ្ហាផ្សេងៗជាដើម។ ជាអកុសល រដ្ឋាភិបាលចាប់ផ្តើមបង្ហាញពីការរឹតត្បិតមកលើសេរីភាពបញ្ចេញមតិនៅលើអ៊ិនធើណែត ដែលរដ្ឋាភិបាលធ្លាប់បានធ្វើអស់រយៈពេលរាប់ឆ្នាំចំពោះប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី។ ឧទាហរណ៍មួយត្រូវបានមើលឃើញក្នុងខែមករា និងខែកុម្ភៈ ឆ្នាំ២០១១ នៅពេលដែលវែបសាយ ខេអាយ មីឌៀ ដែលជាវែបសាយធ្វើការរិះគន់ចំពោះរដ្ឋាភិបាល ត្រូវបានបិទដោយក្រុមហ៊ុនផ្តល់សេវាអ៊ិនធើណែតមួយចំនួន ដោយសារតែមានការស្នើសុំពីមន្ត្រីរដ្ឋាភិបាល។ ផែនការក្នុងពេលថ្មីៗនេះក្នុងការបង្កើតនូវច្បាប់គ្រប់គ្រងប្រព័ន្ធអ៊ិនធើណែតដំបូងបង្អស់ ក៏បានបញ្ជាក់ពីចលនាឆ្ពោះទៅរកការបង្កើននូវការដាក់ពិរុទ្ធលើប្រព័ន្ធអ៊ិនធើណែតផងដែរ។

## ការប្រើប្រាស់អ៊ិនធើណែតនៅកម្ពុជា

ចំនួនអ្នកប្រើប្រាស់អ៊ិនធើណែតនៅកម្ពុជា មានចំនួនទាបខ្លាំងណាស់ប្រសិនបើប្រៀបធៀបជាមួយនឹងចំនួនប្រជាពលរដ្ឋសរុប ប៉ុន្តែចំនួននេះកំពុងតែកើនឡើងយ៉ាងលឿនជាបន្តបន្ទាប់។ ចំនួនអ្នកប្រើប្រាស់អ៊ិនធើណែតកើនឡើងទ្វេដងក្នុងឆ្នាំ២០០៩ ហើយតួលេខបច្ចុប្បន្ននៃការភ្ជាប់ប្រព័ន្ធអ៊ិនធើណែត មានការប៉ាន់ស្មានថាមានប្រហែល ៦៧៩,២៨១ ប៉ុន្តែចំនួននេះមិនមែនរាប់បញ្ចូលទាំងអ្នកដែលបានប្រើប្រាស់អ៊ិនធើណែតនៅតាមហាងកាហ្វេ និងបណ្ណាល័យនៅសកលវិទ្យាល័យនោះទេ។ ថ្វីបើមានការប្រើប្រាស់អ៊ិនធើណែតទាបនៅឡើយ ប៉ុន្តែអ៊ិនធើណែតបានជួយលើកកម្ពស់ការយល់ដឹងនូវបញ្ហារបស់ប្រទេសកម្ពុជាក្នុងចំណោមប្រជាពលរដ្ឋខ្មែរ និងក្នុងសហគមន៍អន្តរជាតិ។ អ៊ិនធើណែតក៏បានផ្តល់នូវមធ្យោបាយសម្រាប់អ្នកសរសេរប្លក់ ភ្នាក់ងារសារព័ត៌មាន អង្គការមិនមែនរដ្ឋាភិបាល ក្រុមប្រឆាំង និងគណបក្សនយោបាយដើម្បីបញ្ជូនសាររបស់ពួកគេទៅកាន់សាធារណជន។ ឧទាហរណ៍ វែបសាយដូចជា យូធ្យូប ត្រូវបានប្រើប្រាស់ដើម្បីផ្សព្វផ្សាយពីភស្តុតាងនៃការរំលោភសិទ្ធិមនុស្ស ឬការបំពានអំណាចរបស់បុគ្គលដែលមានតួនាទីជាអាជ្ញាធរ និងស្ថានីយវិទ្យុដូចជា វិទ្យុសំឡេងសហរដ្ឋអាមេរិក និងវិទ្យុសំឡេងប្រជាធិបតេយ្យអាចផ្សព្វផ្សាយព័ត៌មានរបស់ខ្លួននៅលើអ៊ិនធើណែត។ អ៊ិនធើណែតក៏មានសក្តានុពលក្នុងការផ្លាស់ប្តូរអ្នកប្រើប្រាស់ ពីអ្នកដែលចាំតែទទួលព័ត៌មានទៅជាអ្នកចែកចាយព័ត៌មានដ៏សកម្ម ដែលបញ្ចេញមតិរបស់ពួកគេទៅកាន់សាធារណជនដោយសេរី និងងាយស្រួលធៀបទៅនឹងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណីដែលមានលក្ខណៈ មិនគ្រប់ដណ្តប់បែបនេះ។

## ការឆ្លើយតបរបស់រដ្ឋាភិបាលកម្ពុជា

ដោយសារការអភិវឌ្ឍន៍ផ្នែកព័ត៌មានវិទ្យា និងការកើនឡើងនៃអ្នកប្រើប្រាស់អ៊ិនធើណែត រដ្ឋាភិបាលបានស្នើឲ្យមានការអនុម័តនូវច្បាប់គ្រប់គ្រងប្រព័ន្ធអ៊ិនធើណែត លើកដំបូងបង្អស់ ដើម្បីគ្រប់គ្រងនូវការរីករាលដាលនៃទម្រង់សារព័ត៌មានបែបនេះ និងដើម្បីការពារ "មនុស្សដែលមានចេតនាមិនល្អ ពីការចែកចាយព័ត៌មានមិនពិត"។ ច្បាប់នេះស្ថិត

ក្នុងដំណាក់កាលដំបូងនៃដំណើរការធ្វើសេចក្តីព្រាង និងមិនទាន់ដាក់ឲ្យសាធារណជនបានអាននៅឡើយទេ ប៉ុន្តែមានការភ័យខ្លាចថាច្បាប់បែបនេះអាចនឹងមានផលប៉ះពាល់អាក្រក់មកលើស្ថានភាពសេរីភាពបញ្ចេញមតិនៅលើប្រព័ន្ធអ៊ិនធើណែតនៅកម្ពុជា។ "ព័ត៌មានមិនពិត" អាចត្រូវបានបកស្រាយថា ព័ត៌មាន/គំនិតទាំងឡាយណាដែលផ្ទុយពីផលប្រយោជន៍របស់រដ្ឋាភិបាល និងសមាជិករដ្ឋាភិបាល។ ច្បាប់គ្រប់គ្រងបទល្មើសកុំព្យូទ័ររបស់ប្រទេសថៃ ដែលបានអនុម័តក្នុងឆ្នាំ២០០៧ បានបង្ហាញពីមេរៀនដ៏ល្អមួយ អំពីរបៀបអនុវត្តច្បាប់គ្រប់គ្រងអ៊ិនធើណែតស្រដៀងគ្នានេះនៅកម្ពុជា ផ្ទុយទៅវិញ ជំនួសឲ្យការការពារផលប្រយោជន៍ដល់ប្រជាពលរដ្ឋកម្ពុជា ច្បាប់នេះអាចនឹងមានផលប៉ះពាល់ដែលបង្កគ្រោះថ្នាក់មកលើសេរីភាពផ្នែកនយោបាយ សេរីភាពបញ្ចេញមតិ និងសិទ្ធិដឹង។

## សេចក្តីសន្និដ្ឋាន

កម្ពុជាត្រូវបានចាត់ទុកថាមានប្រវត្តិល្អប្រសើរ នៅពេលនិយាយពីសេរីភាពបញ្ចេញមតិនៅលើអ៊ិនធើណែតជាងប្រទេសដទៃទៀតនៅក្នុងតំបន់។ នៅពេលដែលមន្ត្រីរដ្ឋាភិបាលត្រូវបានសួរនាំស្តីពីស្ថានភាពសេរីភាពបញ្ចេញមតិនៅកម្ពុជា ពួកគេបានលើកយកការមិនគាបសង្កត់លើប្រព័ន្ធអ៊ិនធើណែតមកអះអាង។ ការកើនឡើងនៃចំនួនអ្នកដែលមានលទ្ធភាពប្រើប្រាស់អ៊ិនធើណែត អាចបណ្តាលឲ្យមានច្បាប់គ្រប់គ្រងអ៊ិនធើណែតដ៏តឹងរ៉ឹងមួយ។ ច្បាប់បែបនេះមិនត្រឹមតែផ្ទុយនឹងផលប្រយោជន៍របស់ប្រជាពលរដ្ឋកម្ពុជាទូទៅ ដែលកាន់តែមានលទ្ធភាពប្រើប្រាស់អ៊ិនធើណែតកាន់តែច្រើនប៉ុណ្ណោះទេ ប៉ុន្តែក៏មានលក្ខណៈប្រឆាំងនឹងសេចក្តីប្រកាសរបស់ អង្គការសហប្រជាជាតិ ដែលទាមទារឲ្យមានការការពារនូវមធ្យោបាយថ្មីដែលមានតម្លៃមួយនេះ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង កញ្ញា សន រ៉ាមណា ទូរស័ព្ទលេខ (+៨៥៥ ១៧៦៥ ៥៥ ៩១ ឬ អ៊ីម៉ែល ៖ ramanasorn@cchrcambodia.org +៨៥៥ ៨៩ ៥៨ ៣៥ ៩០) ឬ ចន ខូកលែន ទូរស័ព្ទលេខ ឬ អ៊ីម៉ែល ៖ johncoughlan@cchrcambodia.org ។